**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ត.ក

ភាគីដាក់ឯកសារ: ក្រុមមេធាវីការពារក្តីលោក នួន ជា

ដាក់ជូន: អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៥

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 31-Jul-2015, 09:25
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ (កោសលុប)

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ **សាធារណៈ/Public**

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សារណាឆ្លើយតបរបស់ នួន ជា ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ នួន ជា ជូនអង្គជំនុំជម្រះតុលាការកំពូល ឲ្យស៊ើបអង្កេតបន្ថែមទៅនឹងខ្សែវីដេអូរបស់ផលិតករ ROB LEMKIN និង ថេត សម្បត្តិ**

---

ដាក់ដោយ៖

**ក្រុមមេធាវីការពារក្តី នួន ជា**

សុន អរុណ

Victor KOPPE

ព្រំ ផល្លា

លីវ សុវណ្ណា

Doreen CHEN

Xiaoyang NIE

**ផ្ញើជូន៖**

**សហមេធាវី ខៀវ សំផន**

គង់ សំអុន

Anta GUISSÉ

Arthur VERCKEN

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Nicholas KOUMJIAN

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**PICH Ang**

Marie GUIRAUD

## I. សេចក្តីផ្តើម

១. នៅថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៥ អង្គជំនុំជម្រះតុលាការកំពូលបានចេញសេចក្តីសម្រេចបណ្តោះអាសន្នមួយ ("សេចក្តីសម្រេច") ទាក់ទងនឹងការស៊ើបអង្កេតបន្ថែមដែលខ្លួនបានចាប់ផ្តើមធ្វើ បន្ទាប់ពីមានសំណើពីសហមេធាវីការពារក្តីរបស់លោក នួន ជា ("មេធាវីការពារក្តី") ទៅលើវីដេអូ និងព័ត៌មានរបស់ផលិតករ Rob Lemkin និង ថេត សម្បត្តិ[1]។ នៅក្នុងអំឡុងពេលស៊ើបអង្កេត អង្គជំនុំជម្រះបានស្តាប់ចម្លើយ Rob Lemkin[2] ដែលបន្ទាប់មកបានផ្តល់ជូនអង្គជំនុំជម្រះនូវកំណត់ត្រាដែលគាត់បានរៀបចំសម្រាប់អត្ថបទដែលនឹងចេញផ្សាយ ("កំណត់ត្រា")[3]។ ដោយមានការណែនាំពីអង្គជំនុំជម្រះតុលាការកំពូល នៅថ្ងៃទី១៣ ខែ កក្កដា ឆ្នាំ ២០១៥ មេធាវីការពារក្តីបានសំណើសុំឱ្យទទួលយកកំណត់ត្រាជាភស្តុតាង និងសំណើសុំឱ្យស៊ើបអង្កេតជាក់លាក់ ("សំណើ")[4]។ នៅថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៥ សហព្រះរាជអាជ្ញាបានដាក់សារណាតបទៅនឹងសំណើ ("ចម្លើយតប")[5]។ ដោយអនុលោមតាមមាត្រា ៨.៤ នៃសេចក្តីណែនាំអនុវត្តការដាក់ឯកសារ មេធាវីការពារក្តីសូមដាក់ការឆ្លើយតបទៅនឹងចម្លើយតប[6]។

## II. អំណះអំណាង

---

[1] **F2/4/3/3** "សេចក្តីសម្រេចលើសំណើឱ្យស៊ើបអង្កេតបន្ថែម" ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៥ ("សេចក្តីសម្រេច")។

[2] **F2/4/3/1** "កំណត់ហេតុស្តាប់ចម្លើយសាក្សី Robert T.F. Lemkin" ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១៥។

[3] **F2/4/3/3.1** ឧបសម្ព័ន្ធរបស់ Robert T.F. Lemkin អំពីរបៀបវិវឌឍយោបាយរបស់ រស់ ញឹម, ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០១៥ ("កំណត់ត្រា")។

[4] **F2/4/3/3/1** "ចម្លើយតបរបស់ នួន ជា ទៅនឹងសំណួរនានាស្តីពីកិច្ចស៊ើបសួរបន្ថែមរបស់អង្គជំនុំជំរះតុលាការកំពូលនៅក្នុងឈុតវីដេអូ ដែលជាកម្មសិទ្ធិរបស់ផលិតករភាពយន្ត របស់ ROB LEMKIN និង ថេត សម្បត្តិ" ថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ២០១៥ (សំណើ)។

[5] **F2/4/3/3/3** "ចម្លើយតបរបស់សហព្រះរាជអជ្ញា ទៅនឹងចម្លើយតបរបស់ នួន ជា ទៅនឹងសំណួរនានាស្តីពីកិច្ចស៊ើបសួរបន្ថែមរបស់អង្គជំនុំជំរះតុលាការកំពូលនៅ ក្នុងឈុតវីដេអូ ដែលជាកម្មសិទ្ធិរបស់ផលិតករភាពយន្ត របស់ ROB LEMKIN និង ថេត សម្បត្តិ" ថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ២០១៥ (ចម្លើយតប)។

[6] សេចក្តីណែនាំអនុវត្ត អ.វ.ត.ក/០១/២០០៧/វ.៨ មាត្រា ៨.៤។

## ក. សហព្រះរាជអាជ្ញាអនុវត្តបទដ្ឋានមិនត្រឹមត្រូវស្តីពីការទទួលយកភស្តុតាងថ្មីសម្រាប់បណ្តឹងសាទុក្ខ

២. សហព្រះរាជអាជ្ញាអនុវត្តបទដ្ឋានមិនត្រឹមត្រូវគ្រប់ពេលនៅក្នុងចម្លើយតបរបស់ខ្លួនស្តីពីការទទួលយកភស្តុតាងថ្មីសម្រាប់បណ្តឹងសាទុក្ខ៖សហព្រះរាជអាជ្ញាមិនគិតដល់លក្ខណៈ *de novo* ក្នុងដំណើរការនីតិវិធីនៃបណ្តឹងសាទុក្ខនៅក្នុងប្រព័ន្ធច្បាប់ស៊ីវិល ដោយខ្លួនបានទាមទាច្រើនហួសហេតុទៅលើភាពអាចជឿជាក់បានរបស់ភស្តុតាង។ ហើយខ្លួនក៏បានលើកឡើងខុសទៅលើការទទួលយកភស្តុតាងថ្មីសម្រាប់បណ្តឹងសាទុក្ខសម្រាប់តុលាការមិនអចិន្ត្រៃយ៍។

### *(i) អំណាចរបស់ អជតក ក្នុងការទទួលយកភស្តុតាងថ្មីនៅក្នុងនីតិវិធីច្បាប់ស៊ីវិលគឺទូលំទូលាយ*

៣. ដូចដែលបានលើកឡើងនៅក្នុងបណ្តឹងសាទុក្ខថា អង្គជំនុំជម្រះនេះមានអំណាចទូលំទូលាយក្នុងការទទួលយកភស្តុតាងថ្មី។ វិធាន ១០៤(១) អនុញ្ញាតឱ្យអង្គជំនុំជម្រះតុលាការកំពូល "ត្រួតពិនិត្យភស្តុតាង និង ស្វែងរកភស្តុតាងថ្មី" ដើម្បីសម្រេចលើបណ្តឹងសាទុក្ខ។ អំណាចដ៏ទូលាយនេះគឺស្របទៅនឹងនីតិវិធីនៅក្នុងតុលាការកម្ពុជា និងនៅក្នុងច្បាប់ស៊ីវិលជាទូទៅ ដែលពិចារណាទៅដល់ការវាយតម្លៃ *de novo* នៃភស្តុតាងលើបណ្តឹងសាទុក្ខ[7]។ ដោយមិនគិតដល់ការតវ៉ាដដែល ដែលតូចចិត្ត និងការនាំផ្លូវខុស ដែលថា អង្គជំនុំជម្រះនេះមានកាតព្វកិច្ចការពារបណ្តឹងសាទុក្ខពីការធ្វើឱ្យខូចខាតដល់សវនាការលើកទីពីរ ការពន្យាពេលដំណើរការនីតិវិធី និងឬក៏ជំរុញឱ្យរឿងក្តីមិនគ្រប់លក្ខណៈ"[8]។

៤. វាជារឿងចម្លែក ដោយសារតែនៅពេលដែលអង្គជំនុំជម្រះនេះមានសិទ្ធិអំណាចទទួលពិចារណាលើភស្តុតាងក្នុងនីតិវិធីនេះ សហព្រះរាជអាជ្ញាបែជាស្នើសុំឱ្យបដិសេធកំណត់ត្រានេះទៅវិញ។ អង្គជំនុំជម្រះនេះធ្លាប់បានសម្រេចថា Lemkin គួរតែត្រូវបានស្តាប់ចម្លើយ ហើយខ្លួន

---

[7] **F16** បណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសាលក្រម ក្នុងសំណុំរឿង ០០២/០១ ថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០១៤ (បណ្តឹងសាទុក្ខ) កថាខណ្ឌ ២ ដល់ ១៤។

[8] **F2/4/3/3/3** សំណើរ កថាខណ្ឌ ៣; F2/7/1 "ចម្លើយតបរបស់សហព្រះរាជអជ្ញា ទៅនឹងសំណើទីប្រាំរបស់ នួន ជា សុំឱពិចារណា និងទទួយយកភ័ស្តុតាងបន្ថែមពាក់ព័ន្ធនឹងបណ្តឹងសាទុក្ខ ប្រឆាំងសាលក្រមរបស់អង្គជំនុំជំរះសាលាដំបូងក្នុងសំណុំរឿង" ០០២/០១ ថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ២០១៥ ;F2/6/2 "ចម្លើយតបរបស់សហព្រះរាជអជ្ញា ទៅនឹងសំណើទីបួនរបស់ នួន ជា ស្នើសុំឱពិចារណា និងទទួលយកកភ័ស្តុតាងបន្ថែមពាក់ព័ន្ធនឹងបណ្តឹងសាទុក្ខ ប្រឆាំងនឹងសាលក្រមក្នុង សំណុំរឿង ០០២/០១" ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០១៥ កថាខណ្ឌ ៥។

បានចាប់ផ្តើមស៊ើបអង្កេតសម្រាប់គោលបំណងនេះ។ កំណត់ត្រាគឺជាលទ្ធផលនៃការស៊ើបអង្កេតនឹងត្រូវតែទទួលយកតាមវិធានទូទៅនៃភស្តុតាងដែលមាននៅក្នុងវិធាន ៨៧(៣)។ តម្រូវការនៃវិធាន១០៨(៧) ប្រសិនបើពាក់ព័ន្ធក្នុងការចាប់ផ្តើម គឺត្រូវបានបំពេញនៅពេលដែលអង្គជំនុំជម្រះចាត់តាំងចៅក្រមតំណាងដើម្បីស្តាប់ចម្លើយ Lemkin ។

៥. មេធាវីការពារក្តីកត់សម្គាល់ថា អណត្តិទូលាយបែបនេះក្នុងការបង្ហាញការពិតដែលបានផ្តល់ជូនអង្គជំនុំជម្រះនេះដោយអនុលោមតាមនីតិវិធីច្បាប់កម្ពុជា ក៏ត្រូវបានផ្តល់ជូនដូចគ្នាទៅសហព្រះរាជអាជ្ញាដែលអនុវត្តតួនាទីរបស់ខ្លួនដោយមិនលម្អៀង តែមិនមែនជាភាគីបដិបក្ខយ៉ាងតឹងរឹងនៅក្នុងនីតិវិធីនោះទេ[9]។ តែសហព្រះរាជអាជ្ញានៅតែបន្តតួនាទីរបស់ខ្លួនថា នីតិវិធីទាំងនេះថិតនៅក្នុងច្បាប់អង់គ្លូសាសុង។ មេធាវីការពារក្តីមានការលំបាកក្នុងការយល់អំពីការបដិសេធកំណត់ត្រារបស់ Lemkin ដែលកំពុងថិតនៅក្នុងដៃរបស់អង្គជំនុំជម្រះនេះ ហើយត្រូវបានបង្កើតឡើងតាមរយៈការស៊ើបអង្កេតមួយដែលផ្តួចផ្តើមឡើងដោយអង្គជំនុំជម្រះនេះ ហើយដែលមានភាពពាក់ព័ន្ធជាបឋម និងអាចជឿជាក់បាន និងដែលអាចស្របទៅនឹងកាតព្វកិច្ចរបស់តុលាការនេះក្នុងការស្វែងរកការពិត ឬក៏តាតព្វកិច្ចរបស់សហព្រះរាជអាជ្ញាក្នុងការដើរតួនាទីដោយមិនលម្អៀង។ វាគ្មានមន្ទិលសង្ស័យទេថា "ការទទួលយក" កំណត់ត្រានឹងមិនកើតឡើងនៅក្នុងប្រព័ន្ធច្បាប់ស៊ីវិលនៅក្នុងពិភពលោក ដោយរាប់បញ្ចូលទាំងតុលាការនេះ។

***(ii) បទដ្ឋានអាចជឿជាក់បានទាប***

៦. សហព្រះរាជអាជ្ញាលើកឡើងថា កំណត់ត្រា មិនអាចទទួលយកបានដោយសារតែ "មិនអាចជឿទុកចិត្តបាន" និងមាន "តម្លៃជាភស្តុតាង" ។ សហព្រះរាជអាជ្ញាគាំទ្រដល់អំណះអំណាងនេះដោយចោទប្រកាន់ថា កំណត់ត្រាពឹងផ្អែកជាបឋមទៅនឹងភស្តុតាងអណាមឹក[10] ដែលកំណត់ត្រាមិនមានតម្លៃជាភស្តុតាងដូចនឹងកំណត់ហេតុស្តាប់ចម្លើយដែលធ្វើឡើងដោយ

---

[9] *សូមមើល* ក្រមនីតក្រមនីតិវិធីព្រហ្មទណ្ឌបារាំង មាត្រា ៣១ ("Le ministère public exerce l'action publique et requiert l'application de la loi, dans le respect du principe d'impartialité auquel il est tenu.")។

[10] F2/4/3/3/3 ចម្លើយតប កថាខណ្ឌ ១០។

Philip Short, Stephen Heder និង François Ponchaud[11] ដោយសារតែ Lemkin និង ថេត សម្បត្តិ មិនបានពន្យល់ឲ្យបានគ្រប់គ្រាន់អំពីវិធីសាស្ត្រ[12]ដែលកំណត់ត្រាបានយោងទៅ [redacted] ហើយដែលថា សម្បត្តិ មានទំនាក់ទំនងជាមួយ នួន ជា[14] (គឺគ្មានមូលដ្ឋាន)។ ពុំមានការចោទប្រកាន់ណាមួយទាក់ទងនឹងភាពជឿជាក់បាននៃភស្តុតាងនោះទេ។

៧. វិធាន ១០៨(៧) ចែងក្នុងផ្នែកពាក់ព័ន្ធថា:

> ភាគីអាចស្នើសុំបន្ថែមភស្តុតាងចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល យោងតាម វិធាន ៨៧(៣) បើសិនជាភស្តុតាងនោះ មិនអាចរកបានក្នុងពេលសវនាការ ហើយ ដែលអាចជាកត្តាកំណត់នាំឲ្យឈានដល់ការធ្វើសេចក្តីសម្រេចនៅក្នុងសវនាការ។

អាស្រ័យហេតុនេះហើយវិធាន ១០៨(៧) តម្រូវត្រឹមតែភស្តុតាងដែលត្រូវទទួលយកបំពេញតាមវិធាន ៨៧(៣) ដែលជាបញ្ញតិទូទៅសម្រាប់ការទទួលយកភស្តុតាងនៅក្នុងពេលសវនាការ និងបន្ថែមពីលើនេះទៀតនោះគឺ "អាចកត្តាដែលនាំដល់ការសម្រេចនៅក្នុងពេលសវនាការ"។ វិធាន ១០៨(៧) មិនបាននិយាយទៅដល់បញ្ញាតិណាមួយអំពីភាពអាចជឿជាក់បាននូវភស្តុតាងនោះទេ។ ភាពអាចជឿជាក់បានរបស់ភស្តុតាងសម្រាប់ការទទួលយកសម្រាប់បណ្តឹងសាទុក្ខ គឺដូចគ្នាទៅនឹងបទដ្ឋានដែលកំពុងអនុវត្តនៅពេលសវនាការ។

៨. ដូចដែលបានលើកឡើងនៅក្នុងបណ្តឹងសាទុក្ខថា អង្គជំនុំជម្រះបានអនុវត្តវិធាន ៨៧(៣) ក្នុងការទទួលយកភស្តុតាងរាប់ពាន់ដោយពុំពិចារណាឲ្យបានល្អិតល្អន់ទៅលើកាលៈទេសៈដែលភស្តុតាងត្រូវបានបង្កើតឡើងនោះទេ[15]។ ឯកសារទាំងនេះរួមមានកិច្ចសម្ភាសន៍ដែលមិនមានយថាភូត ដែលបង្កើតឡើងនៅក្នុងកាលៈទេសៈមិនច្បាស់លាស់ដោយសាស្ត្រាចារ្យស្រាវជ្រាវ

---

[11] **F2/4/3/3/3** ចម្លើយតប កថាខណ្ឌ ១១ដល់ ១៥។

[12] **F2/4/3/3/3** ចម្លើយតប កថាខណ្ឌ ១៦។

[13] **F2/4/3/3/3** ចម្លើយតប កថាខណ្ឌ ១៧។

[14] **F2/4/3/3/3** ចម្លើយតប កថាខណ្ឌ ១៨-១៩។

[15] **F16** បណ្តឹងសារទុក្ខ កថាខណឌ ១៥៦-១៥៨។ សូមមើលផងដែរ E185 (និងឧបសម្ព័ន្ធដែលភ្ជាប់ជាមួយ) E185/1(និងឧបសម្ព័ន្ធដែលភ្ជាប់ជាមួយ) E185/2 (និងឧបសម្ព័ន្ធដែលភ្ជាប់ជាមួយ) E299 (និងឧបសម្ព័ន្ធដែលភ្ជាប់ជាមួយ)

អ្នកស្រាវជ្រាវ និងរដ្ឋាភិបាលបរទេស ដែលស្នាដៃរបស់គាត់មិនដែលត្រូវបានត្រួតពិនិត្យដោយហ្មត់ចត់ដោយស្ថាប័នតុលាការ និងសៀវភៅទាំងមូលពោរពេញទៅដោយគំនិតលាយឡំមិនច្បាស់លាស់ និងការលើកឡើងអំពីអង្គហេតុមិនមែនជាសារធាតុ។ ទស្សនដែលថាកំណត់ត្រារបស់ Lemkin ចេញពីកិច្ចសម្ភាសន៍ចំនួនបួនដែលគាត់បានចូលរួម និងគាត់ថតជាវីដេអូមិនបំពេញតាមបទដ្ឋាននេះ គឺជារឿងគួរឲ្យអស់សំណើចមួយ ហើយចុះហេតុអ្វីបានជាសហព្រះរាជអាជ្ញាមិនព្យាយាមចង្អុលបង្ហាញជាភស្តុតាង។

***(iii) សហព្រះរាជអាជ្ញាលើកឡើងខុសអំពីបទដ្ឋានសម្រាប់ការទទួលយកភស្តុតាងថ្មីនៅតុលាការអន្តរជាតិផ្សេងទៀត***

៩. បើទោះជាអង្គជំនុំជម្រះនេះទទួលយកវិធានច្បាប់អង់គ្លូសាសុងទៅលើបទដ្ឋានទទួលយកភស្តុតាងថ្មីក៏ដោយ ក៏សហព្រះរាជអាជ្ញាលើកឡើងខុសអំពីបទដ្ឋានពាក់ព័ន្ធជាធរមានសម្រាប់ការទទួលយកភស្តុតាងថ្មីសម្រាប់បណ្តឹងសាទុក្ខនៅតុលាការអន្តរជាតិផ្សេងទៀតដែលប្រើប្រាស់ច្បាប់អង់គ្លូសាសុង។ ខណៈដែលសហព្រះរាជអាជ្ញាលើកឡើងជាដដែលៗថា សំណើខកខានមិនបានលើកឡើងថា កំណត់ត្រា "*នឹង* ជាកត្តាសម្រេចនៅក្នុងបណ្តឹងសាទុក្ខ"[16] យុត្តិសាស្ត្រច្បាប់ទាមទាតែការបង្ហាញមួយដែលថា សាលក្រមអាចត្រូវបានធ្វើឲ្យប៉ះពាល់។ ភាពខុសប្លែកគ្នានេះត្រូវបានទទួលស្គាល់យ៉ាងល្អនៅក្នុងយុត្តិសាស្ត្រច្បាប់។ ដូចដែលសាលឧទ្ធរណ៍នៅ ICTY សម្រេចនៅក្នុងសំណុំរឿង *Kupreškić:*

> នៅក្នុងការកំណត់ថាតើភស្តុតាងថ្មីនឹងអាចបង្ហាញថា ការផ្តន្ទាទោស ឬការកាត់ទោសមិនមានសុវត្ថិភាព ដើម្បីសម្រេចលើសារណាវិធាន១១៥ជាច្រើននៅក្នុងសំណុំរឿងនេះ សាលាឧទ្ធរណ៍បានពិនិត្យជាដំបូងទៅលើមូលហេតុ និងភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះក្នុងការសម្រេច។ បន្ទាប់មកពីពិចារណាលើសារណារបស់ភាគី សាលាឧទ្ធរណ៍ បានចេញសេចក្តីសម្រេចមួយថា តើភស្តុតាងថ្មីអាចមានផលប៉ះពាល់ដល់សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការផ្តន្ទាទោសឬក៏អត់។ ការអនុវត្តលើគោលការណ៍នេះត្រូវបានបញ្ជាក់តាមវិធីផ្សេងគ្នា។ ឧទាហរណ៍ "ប្រសិន

---

[16] **F2/4/3/3/3** ចម្លើយតប កថាខណ្ឌ ២១, ២៩។

បើភស្តុតាងដែលបានស្នើសុំខ្លះ ត្រូវបានបង្ហាញជូនអង្គជំនុំជម្រះ ក្នុងពេលសវនាការ និងត្រូវបានទទួលយក នោះវាអាចប៉ះពាល់ដល់សេចក្តីសម្រេចខ្លះរបស់អង្គជំនុំជម្រះសាលាដំបូងដែលនាំទៅដល់ការសម្រេចដើម្បីផ្តន្ទាទោសអ្នកប្តឹងសាទុក្ខ"។ វានឹងប្រហែលជាបង្ហាញថា ការផ្តន្ទាទោស និងការកាត់ទោសគឺមិនមានសុវត្ថិភាព"។ ភស្តុតាងនេះអាចមានភាពប៉ះពាល់ដល់សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងពេលសវនាការ"។ ហើយ "ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងមានភស្តុតាងដូចនេះនៅចំពោះមុខខ្លួន នោះវានឹងមានសេចក្តីសម្រេចផ្សេងពីនេះ"។ <u>ទោះបីជាបញ្ជាក់តាមវិធីផ្សេងៗក្តី ក៏ការវាយតម្លៃជាក់ស្តែងចំពោះបទដ្ឋានបានអនុវត្តពេញដំណើរការវិធាន១១៥ បង្ហាញថា គឺថិតនៅក្រោមតម្រូវការចង្អៀត ដែលភស្តុតាងថ្មីនឹងមានផលប៉ះពាល់ដល់សេចក្តីសម្រេចរបស់អង្គជំនុំជម្រះ និងមានទំនាក់ទំនងគ្នាទៅនឹងការសាកល្បងមួយថា តើភស្តុតាងថ្មីអាចមានផលប៉ះពាល់ដល់សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងឬក៏អត់។</u>

[...]

សាលាឧទ្ធរណ៍ពិតជាបានឆ្លៀតយកឱកាសនេះ ដើម្បីបញ្ជាក់ថា តាមទស្សនរបស់ខ្លួន បទដ្ឋានកាន់តែត្រឹមត្រូវសម្រាប់ការទទួលយកភស្តុតាងថ្មីតាមវិធាន១១៥សម្រាប់បណ្តឹងសាទុក្ខ គឺថាតើភស្តុតាងនោះ "អាច" មានផលប៉ះពាល់ដល់សាលក្រម ជាជាងថាតើវា "នឹងអាច" បានធ្វើដូច្នោះឬក៏អត់[17]។

អាស្រ័យហេតុនេះ សំណើសុំសម្រាប់ភស្តុតាងបន្ថែមត្រូវបានបដិសេធចោលនៅពេលណាដែល "ភស្តុតាងមិនអាចមានធ្វើឲ្យមានការផ្លាស់ប្តូរ"[18]។

## ខ. សហព្រះរាជអាជ្ញាមិនយកចិត្តទុកដាក់លើកិច្ចខិតខំរបស់មេធាវីការពារក្តីក្នុងការពន្យល់ពីហេតុផលរបស់ភស្តុតាងនេះនៅពេលសវនាការ

១០. បើទោះជាកំណត់ត្រា ត្រូវបានទទួលយកនៅក្នុងកាលៈទេសៈណាក៏ដោយតាមវិធាន១០៨(៧) និង ១០៤(១) មេធាវីការពារក្តីកត់សម្គាល់ថា ខ្លួនបានស្នើសុំការស៊ើបអង្កេតលើឯកសារ

---

[17] បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសាលក្រម *Kupreškić* កថាខណ្ឌ ៦៦ ដល់ ៦៨។

[18] បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសាលក្រម *Kupreškić* កថាខណ្ឌ ៦៦។

របស់ Lemkin និង ថេត សម្បត្តិ នៅក្នុងពេលសវនាការ[19]។ សំណើនោះត្រូវបានបដិសេធ[20] តាមរយៈសេចក្តីសម្រេចដែលមេធាវីការពារក្តីប្តឹងសាទុក្ខ[21]។ អាស្រ័យហេតុនេះហើយ កំណត់ត្រាត្រូវតែទទួលយក ដោយមិនគិតដល់បទដ្ឋានជាធរមានសម្រាប់ការទទួលយកភស្តុតាងថ្មី ថាជាការប៉ះប៉ូវដល់ការខកខានរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការទាក់ទងជាមួយ Lemkin និង ការរំលោភដល់សិទ្ធិរបស់នួនជាក្នុងការការបង្ហាញការការពារក្តី។

## គ. កំណត់ត្រាពិតជាគួរឱ្យជឿជាក់បាន

១១. ផ្ទុយពីការលើកឡើងរបស់សហព្រះរាជអាជ្ញា កំណត់ត្រាគឺពិតជាគួរឱ្យជឿជាក់បានខ្លាំងណាស់។ កិច្ចសម្ភាសន៍ ត្រូវបានធ្វើឡើងដោយកិច្ចសហការរវាង ថេត សម្បត្តិ ដែលជាអ្នកកាសែតមានបទពិសោធន៍ម្នាក់ ដែលខ្លួនបានធ្វើការស្រាវជ្រាវជាងមួយទស្សវត្សរ៍ទៅលើកម្ពុជាប្រជាធិបតេយ្យ តាមរយៈកិច្ចសម្ភាសន៍ជាងមួយពាន់ម៉ោងសម្រាប់ប្រធានបទជាច្រើនជាមួយនឹង Rob Lemkin ជាផលិតករដែលមានការអប់រំពី Oxford និងជាអ្នកកាសែតដែលមានបទពិសោធន៍រាប់ទស្សវត្សរ៍រួមទាំង BBC2 និង BBC World Service[22] ហើយក៏ជាសាច់ញាតិជីដូនមួយឆ្ងាយរបស់ Raphael Lemkin និងត្រូវបានជំរុញក្នុងការការងាររបស់គាត់យ៉ាងហោចណាស់ក៏ដោយសារតែបទពិសោធន៍គ្រួសារផ្ទាល់ខ្លួននៅក្នុងរបបណាស៊ីប្រទេសអាល្លឺម៉ង់[23]។ ដូចដែល Lemkin បានពន្យល់ជូនចៅក្រមពីររូបនៃអង្គជំនុំជម្រះនេះថា គាត់ជាផលិតករខ្សែភាពយន្តដោយឯករាជ្យអស់រយៈពេល៣០ឆ្នាំកន្លងមក ដែលគាត់បាន

---

[19] **E294** “សំណើសុំទទួលយកភ័ត្តុតាងថ្មី កោះហៅ ROB LEMKIN និងចាប់ផ្តើមការស៊ើបអង្កេត” ថ្ងៃទី ១១ ខែកក្កដា ឆ្នាំ២០១៣ ។

[20] **E294/1**“សេចក្តីសម្រេចលើសំណើរបស់ នួន ជា ស្នើសុំឲទទួលយកភ័ស្តុតាងថ្មី ឲចាប់ផ្តើមកការស៊ើបអង្កេត និងកោះហៅលោក ROB LEMKIN” ថ្ងៃទី ២៤ ខែកក្កដា ឆ្នាំ២០១៣។

[21] **F16** បណ្តឹងសាទុក្ខ កថាខណ្ឌ ៨៣ , ៧០៣ (ខ)។

[22] **F2/4/3/1**, “កំណត់ហេតុស្តាប់ចម្លើយសាក្សី -Robert T.F. Lemkin” ថ្ងៃទី ១៨ ខែឧសភា ឆ្នាំ២០១៥ (កំណត់ហេតុស្តាប់ចម្លើយសាក្សី Lemkin)

[23] សូមមើលដូចជា “រឿងរ៉ាវអំពើប្រល័យពូជសាសន៍ទីពីរ “សត្រូវ” Jewish Journal ថ្ងៃទី ១៣ ខែ មករា ឆ្នាំ២០១១។

ផលិតខ្សែភាពយន្តឯកសារមិនក្រោម៥០នោះទេ[24]។ ចាប់តាំងពីឆ្នាំ១៩៩៩ រហូតដល់ ២០០៦ "គាត់បានដឹកនាំនាយកដ្ឋានអ្នកកាសែតស៊ើបអង្កេតសម្រាប់ទូរទស្សន៍លេខ៤នៅចក្រភពអង់គ្លេស"[25]។ ដូចដែលសំណើបានបញ្ជាក់ថា Lemkin បានប្រើប្រាស់ជំនាញគួរឱ្យកត់សម្គាល់នេះដើម្បីធានាថា កិច្ចសម្ភាសន៍ត្រូវបានធ្វើឡើងដោយបទដ្ឋានខ្ពស់បំផុតក្នុងចំណោមអ្នកកាសែត។ កិច្ចសម្ភាសន៍ត្រូវបានធ្វើឡើងជាមួយតែនឹងប្រធានបទ ដែលអាចផ្តល់ជូននូវរឿងរ៉ាវជាដំបូងទៅលើព្រឹត្តិការណ៍ ដែលកំពុងពិពណ៌នា[26]។ ប្រធានបទនីមួយៗ ត្រូវបានសម្ភាសន៍ជាច្រើនដង "ច្រើនជាង១០ដង" និង "កិច្ចខិតខំប្រឹងប្រែងត្រូវបានធ្វើឡើងដើម្បីផ្ទៀងផ្ទាត់ឬក៏បន្ថែមព័ត៌មានតាមរយៈការសួរបុគ្គលផ្សេងទៀតតាមរយៈព័ត៌មានដែលផ្តល់ជូនដោយបុគ្គលម្នាក់"[27]។ កិច្ចសម្ភាសន៍ត្រូវបានធ្វើឡើងនៅ "ទីតាំងផ្សេងគ្នា និងពេលវេលាខុសគ្នា"[28]។ កំណត់ហេតុវីដេអូលើប្រធានបទខ្លះត្រូវបានបង្ហាញជូនទៅលើប្រធានបទផ្សេងទៀតដើម្បីវាស់ស្ទង់ប្រតិកម្មរបស់គេ[29]។

១២. កំណត់ត្រាគ្រាន់តែបញ្ជាក់ពីការពិពណ៌នារបស់ Lemkin ចំពោះកិច្ចសម្ភាសន៍ដូចគ្នាទាំងនេះ។ Lemkin បានប្រាប់ចៅក្រមនៃអង្គជំនុំជម្រះនេះអំពីការចូលរួមយ៉ាងជ្រៅរបស់ខ្លួនក្នុងដំណើរការជ្រើសរើសសាក្សី ការធ្វើពង្រាងសំណួរ ការធ្វើប្រតិចារិត និងការផ្ទៀងផ្ទាត់ខ្សែវីដេអូ[30]។ រាល់កិច្ចសម្ភាសន៍ទាំងអស់ត្រូវបានធ្វើឡើងដែលជាផ្នែកមួយនៃការផលិតខ្សែភាពយន្តដែល Lemkin នៅតែសង្ឃឹមថា នឹងចេញជារូបរាង[31]។ អាស្រ័យហេតុនេះហើយ Lemkin មាន

[24] **F2/4/3/1** កំណត់ហេតុស្តាប់ចម្លើយសាក្សី Lemkin។

[25] **F2/4/3/1** កំណត់ហេតុស្តាប់ចម្លើយសាក្សី Lemkin។

[26] **F2/4/3/1** កំណត់ហេតុស្តាប់ចម្លើយសាក្សី Lemkin។

[27] **F2/4/3/3/1** សំណើ កថាខណ្ឌ ៧។

[28] **F2/4/3/1** កំណត់ហេតុស្តាប់ចម្លើយសាក្សី Lemkin.

[29] **F2/4/3/1** កំណត់ហេតុស្តាប់ចម្លើយសាក្សី Lemkin។

[30] **F2/4/3/1** កំណត់ហេតុស្តាប់ចម្លើយសាក្សី Lemkin។

[31] **F2/4/3/1** កំណត់ហេតុស្តាប់ចម្លើយសាក្សី Lemkin។

ការ "យល់ដឹងច្រើន" អំពីខ្មែរក្រហម ដែលគ្មានបុគ្គលណាម្នាក់រួមទាំង ថេត សម្បត្តិផង អាចដឹងបាន[32]។

១៣. បើទោះជាមាននៅក្នុងសារណាឆ្លើយតបរបស់ខ្លួនក៏ដោយ ក៏សហព្រះរាជអាជ្ញាបានអះអាងដដែលៗ អំពីភាពជឿជាក់បានមិនមែនសម្រាប់តែកិច្ចសម្ភាសន៍ទាំងបួនដែលលើកឡើងនៅក្នុងកំណត់ត្រានោះទេ ក៏ប៉ុន្តែសម្រាប់កិច្ចសម្ភាសន៍ដែលយោងនៅក្នុងខ្សែភាពយន្ត។ សហព្រះរាជអាជ្ញាបានស្នើសុំឱ្យទទួលយកជាភស្តុតាង[33] និងយោងជាបន្តបន្ទាប់នៅក្នុងសវនាការ[34] និងលើបណ្តឹងសាទុក្ខ[35]។ មេធាវីការពារក្តីមិនបានដឹងអំពីឯកសារអំពីកម្ពុជាប្រជាធិបតេយ្យដែលផលិតដោយ ថេត សម្បត្តិ ឬ Rob Lemkin ដែលសហព្រះរាជអាជ្ញាមិនបានស្នើសុំជាបន្ទាន់ឱ្យទទួលយកជាភស្តុតាងនៅក្នុងដំណើរការនីតិវិធីនេះ។ សហព្រះរាជអាជ្ញាបានប្រកាសនៅក្នុងសារណារបស់ខ្លួននៅចំពោះមុខអង្គជំនុំជម្រះនេះនៅខែកញ្ញា កន្លងទៅថា "ជំនាញស៊ើបអង្កេតរបស់ ថេត សម្បត្តិ គឺមិនបាច់មានការឆ្ងល់ទេ"[36]។

---

[32] **F2/4/3/1** កំណត់ហេតុស្តាប់ចម្លើយសាក្សី Lemkin។

[33] **E93/7** "សំណើរបស់សហព្រះរាជអជ្ញា សុំឱស្តាប់អ្នកជំនាញ ២រូប និងសាក្សី ១៣រូប បន្ថែមនៅក្នុងតំណាក់កាលដំបូងនៃសវនាការ និងការជូនដំណឹងអំពីចេតនាដាកឈុតវិដេអូខ្លីៗចំនួន៧ ទាក់ទងទៅនឹង នួន ជា នៅចំពោះមុខអង្គជំនុំជំរះសាលាដំបូង ដោយអនុលោមតាមវិធាន ៨៧(៤)" ថ្ងៃទី ៥ ខែកក្កដា ឆ្នាំ២០១១ កថាខណ្ឌ ៣៣-៣៤; ថ្ងៃមួយនៅពោធិ៍ជ្រៃ, មើល **E186** ការដាក់បង្ហាញឯកសាររបស់សហព្រះរាជអជ្ញា ស្តីពីខ្សែភាពយន្តឯកសារ ដែលមានចំណងជើងថា "សត្រូវរបស់ប្រជាជន" ថ្ងៃទី ១៧ ខែមេសា ឆ្នាំ២០១២; មើលផងដែរ **E152**។

[34] E295/6/1, "សេចក្តីសន្និដ្ឋានបញ្ចប់របស់សហព្រះរាជអាជ្ញាក្នុងសំណុំរឿង ០០២/០១" ថ្ងៃទី២៧ កញ្ញា ឆ្នាំ២០១៣ កថាខណ្ឌ 120, 312, 445, 446, 455, 465, 467, 468, 469, 501,504. យោងទៅលើការងាររបស់ Rob Lemkin និង ថេត សម្បត្តិ នៅក្នុងសេចក្តីសន្និដ្ឋានបិទរបស់សហព្រះរាជអាជ្ញាដោយរាប់បញ្ចូលទាំងខ្សែភាពយន្តសត្រូវប្រជាជន ថ្ងៃមួយនៅទួលពោធិជ្រៃ និងនៅពីក្រោយការសម្លាប់។ សូមមើលផងដែរប្រតិចារិតសវនាការ **E1/212.2** ថ្ងៃទី២៥ ខែ មិថុនា ឆ្នាំ ២០១៣ ទំព័រ 34-35; ប្រតិចារិតសវនាការ ថ្ងៃទី២៧ ខែ មិថុនា ឆ្នាំ២០១៣ **E1/214.1** ទំព័រ19-23, 45, 47-53, 59។

[35] **F17/1**, "ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងសាទុក្ខសំណុំរឿង ០០២/០១" ថ្ងៃទី ១៤ ខែ មេសា ឆ្នាំ ២០១៥ ជើងទំព័រ 1417, 1726, 2166, 2363, 2380, 2394។

[36] **F2/2** "ចម្លើយតបរបស់សហព្រះរាជអជ្ញាទៅនឹងសំណើទីមួយ និងទីពីររបស់មេធាវីការពារក្តី នួន ជា សុំឱទទួលយក និងពិចារណាទៅលើភស្តុតាងបន្ថែម ទាក់ទងនឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជុំនំជម្រះសាលាដំបូងក្នុង

១៤. ប្រការគួរឲ្យងឿងឆ្ងល់បំផុតនោះគឺបើតាមការអះអាងរបស់សហព្រះរាជអាជ្ញា គឺវិធីសាស្ត្រក្នុងការសម្ភាសន៍ ដែលខ្លួនផ្ទាល់បានយោងយ៉ាងច្រើននោះ ថាមិនគួរឲ្យជឿជាក់បានទៅវិញ។ សហព្រះរាជអាជ្ញាព្យាយាមការពារខ្លួនអំពីការជំទាស់ទៅនឹងភាពផ្ទុយគ្នាយ៉ាងច្បាស់នេះដោយបែងចែករវាង Lemkin និង ថេត សម្បត្តិ។ ក្រៅពីភាពមិនទំនងយ៉ាងជាក់ច្បាស់អំពីការបកស្រាយខុសរបស់ខ្លួនអំពីជំនាញរបស់ Lemkin[37] សហព្រះរាជអាជ្ញាប្រហែលជាសង្ឃឹមថា អង្គជំនុំជម្រះនេះនឹងភ្លេចថា បទសម្ភាសន៍នេះត្រូវបានធ្វើឡើងជាផ្នែកមួយយ៉ាងពិតប្រាកដនៃដំណើរការដូចគ្នាក្នុងការផលិតខ្សែភាពយន្ត *Enemies of the People* និង *One Day at Po Chrey*។ សហព្រះរាជអាជ្ញាជំទាស់លើមូលហេតុដែលថា Lemkin មិនមានសមត្ថភាពផ្តល់អនុសាសន៍ទៅលើកិច្ចសម្ភាសន៍ដែលធ្វើឡើងដោយ ថេត សម្បត្តិ នោះទេ[38] ហើយលើកឡើងដដែលថា វិធីសាស្ត្រក្នុងការសម្ភាសន៍របស់ Lemkin មិនអាចឲ្យជឿជាក់បានោះទេ។ សហព្រះរាជអាជ្ញាប្រហែលជាអាចចាប់ផ្តើមតាមរយៈការសម្រេចថា អ្នកដែលខ្លួនគិតថាបានធ្វើបទសម្ភាសន៍ ហើយថាតើគាត់មានសមត្ថភាពក្នុងការធ្វើបទសម្ភាសន៍ឬក៏អត់។

១៥. ភាពចម្លែកដូចគ្នាមួយទៀតនោះ គឺការលើកឡើងរបស់សហព្រះរាជអាជ្ញាថា កិច្ចសម្ភាសន៍មិនអាចជឿជាក់បាន ពិព្រោះវាគ្រាន់តែជាសំដីមួយរបស់ នួន ជា អាស្រ័យហេតុនេះហើយផ្តល់ឲ្យគាតន់នូវ "វិធីមួយក្នុងការផ្តល់សក្ខីកម្ម ដោយពុំចាំបាច់ធ្វើតេស្តពីសោធលើការអះអាងរបស់គាត់ទៅតាមវិធីដ៏មានអត្ថន័យ ដែលការសួរសាក្សីរបស់ភាគីបដិបក្ខធ្លាប់ត្រូវបានអនុញ្ញាតឲ្យធ្វើនោះឡើយ"[39]។ ជាថ្មីម្តងទៀតទស្សនះរបស់សហព្រះរាជអាជ្ញាទៅលើកិច្ចសម្ភាសន៍របស់ Lemkin និង សម្បត្តិ ដោយរាប់បញ្ចូលទាំង "ដំណើរការនៃការធ្វើសេចក្តីសម្រេចអំពីថាតើជាមួយនរណា ដែលត្រូវធ្វើសម្ភាស តើសំនួរឬសម្ភារៈឯកសារអ្វីខ្លះដែលត្រូវសួរទៅកាន់សាក្សីនានា ហើយថាតើសម្ភារៈឯកសារអ្វីខ្លះដែលត្រូវជ្រើសរើសសម្រាប់ខ្សែភាព

---

សំណុំរឿង ០០២/០១" ថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ២០១៤ (សហព្រះរាជអជ្ញា ចម្លើយតបទៅនឹងសំណើទីមួយ និងទីពីរ) កថាខណ្ឌ ១០។

[37] សូមមើល កថាខណ្ឌ ១១ ខាងលើ។

[38] **F2/2**, "ចម្លើយតបសហព្រះរាជអជ្ញាទៅនឹងសំណើទីមួយ និងទីពីរ" កថាខណ្ឌ ១៦។

[39] **F2/4/3/3/3** ចម្លើយតប កថា ខណ្ឌ ១៩។

យន្ត និងសៀវភៅរបស់ពួកគាត់"[40] គឺខុសគ្នានៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដែលខ្លួនបានស្នើសុំម្តងហើយម្តងទៀតឲ្យទទួលស្គាល់និងយោងទៅលើសៀវភៅរបស់ សម្បត្តិ និង ទាំងខ្សែភាពយន្តរបស់ Lemkin និង សម្បត្តិ[41]។ សហព្រះរាជអាជ្ញាអស់សង្ឃឹមជាខ្លាំងក្នុងការរកបានអ្នកផ្តល់បទសម្ភាសន៍ដែលបង្ហាញតាមរយៈ "ដំណើរការសម្រេចចិត្ត" របស់ Lemkin និង សម្បត្តិ ដែលខ្លួនបានទទួលយកក្នុងសវនាការជាសាធារណៈថា ជាការសំខាន់ក្នុងការស្តាប់ចម្លើយសាក្សីខ្លះក្នុងចំណោមអ្នកផ្តល់បទសម្ភាសន៍ទាំងនេះក្នុងឋានៈជាសាក្សី ដើម្បីធានាថា គាត់មាន "ឱកាសគ្រប់គ្រាន់" ដើម្បីបង្ហាញថា ការសម្លាប់នៅទួលពោធិជ្រៃពិតជាកើតមាន[42]។ នេះជាជម្រើសយុទ្ធសាស្ត្រមួយដ៏ឆ្លាត ដោយសារតែបុគ្គលដែលត្រូវបានសម្ភាសន៍ និងថតដោយ Lemkin និង សម្បត្តិ បានផ្តល់តែភស្តុតាងដែលអាចជឿជាក់បានតែអំពីការសម្លាប់នៅក្នុងសំណុំរឿងតែប៉ុណ្ណោះ[43]។ អង្គជំនុំជម្រះតុលាការកំពូលអាចស្ងប់ចិត្តថា វាមិនមែនជាគោលបំណងនៃការនាំទៅដល់ភស្តុតាងដោះបន្ទុកដែលថា សំណើសម្រាប់ភស្តុតាងនេះត្រូវបានបង្កើតឡើង។

១៦. សហព្រះរាជអាជ្ញាផ្សំចូលគ្នានូវមូលហេតុមិនច្បាស់លាស់អំពីអំណះអំណាងរបស់ខ្លួនក្នុងការញែកឲ្យដាច់ពីគ្នារវាងជំនាញរបស់ Lemkin និង Philip Short, François Ponchaud និង Stephen Heder។ អំណះអំណាងដំបូងគឺ (ជាថ្មីម្តងទៀត) មិនត្រឹមត្រូវទេ ដោយសារតែកិច្ចសម្ភាសន៍ត្រូវបានធ្វើឡើងដោយ Lemkin និង សម្បត្តិ អាស្រ័យហេតុនេះហើយវាជាជំនាញរួមគ្នាមួយដែលបង្កើតជាមូលដ្ឋានសមស្របក្នុងការប្រៀបធៀប។ តែបើទោះជាការលើកឡើងដំបូងខុសបែបនេះក៏ដោយ ក៏កំណត់ត្រាត្រូវបានឃើញថា គួរឲ្យជឿជាក់បានជាងបទសម្ភាសន៍ដែលធ្វើឡើងដោយ Ponchaud, Short ឬ Heder ។

១៧. ការវិភាគរបស់សហព្រះរាជអាជ្ញាទៅលើកិច្ចសម្ភាសន៍ដែលធ្វើឡើងដោយ Ponchaud, Short និង Heder និងពឹងផ្អែកយ៉ាងច្រើននៅក្នុងសាលក្រមថាជាភស្តុតាងសំខាន់ក្នុងការគាំទ្រអំណះ

[40] **F2/4/3/3/3** ចម្លើយតប កថា ខណ្ឌ ១៨។

[41] សូមមើល កថាខណ្ឌ ១៣ ខាងលើ។

[42] ប្រតិចារិតសវនាការថ្ងៃទី ១៣ មិថុនា ឆ្នាំ ២០១៣ (កិច្ចប្រជុំរៀបចំសវនាការ **E1/207.1** ) ទំព័រ ៧១។

[43] **F16** បណ្តឹងសាទុក្ខ កថាខណ្ឌ ៥៤៩ដល់ ៥៥០។

អំណាងរបស់ខ្លួនទៅលើបញ្ហាចោទនេះគឺជាការនាំផ្លូវមិនត្រឹមត្រូវ។ ការពិភាក្សាគឺផ្តោតស្ទើរតែទាំងស្រុងទៅលើជំនាញរបស់សាក្សីអំពីប្រទេសកម្ពុជា និង កម្ពុជាប្រជាធិបតេយ្យ និងបន្តកិច្ចខិតខំរបស់សហព្រះរាជអាជ្ញាក្នុងការមិនផ្តល់តម្លៃតាមមធ្យោបាយផ្សេងៗទៅលើសាក្សីដែលខ្លួនបានយោងយ៉ាងច្រើនទៅលើការងាររបស់គាត់នៅក្នុងសំណុំរឿង ០០២ និងបន្តដកស្រង់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។ ប៉ុន្តែមេធាវីការពារក្តីមិនបានស្នើសុំឱ្យទទួលយកទស្សនៈរបស់ Lemkin ជាភស្តុតាង ឬក៏ចាត់ទុក Lemkin ជាសាក្សីជំនាញនោះទេ ហើយក៏មិនស្នើថាគាត់មានជំនាញជាង Short, Ponchaud ឬ Heder នោះទេ។ មេធាវីការពារក្តីស្នើសុំឱ្យទទួលយកជាភស្តុតាងនូវកំណត់ត្រារបស់ Lemkin ទៅលើបទសម្ភាសន៍ដែលគាត់ផ្តួចផ្តើម ធ្វើគម្រោង ចូលរួម និងពិនិត្យពិចៃយ៉ាងហ្មត់ចត់។ បញ្ហានៅចំពោះមុខអង្គជំនុំជម្រះនេះគឺមិនមែនអំពីថាតើ Heder មានចំណេះដឹងច្រើនជាង Lemkin អំពីកម្ពុជាប្រជាធិបតេយ្យនោះទេ តែវាជាបញ្ហាថាតើអ្នកណាផ្តល់រឿងរ៉ាវដែលអាចជឿទុកចិត្តបានច្រើនជាង។

១៨. នៅក្នុងករណីនេះសញ្ញាសំគាល់ច្បាស់នៃភាពអាចទុកចិត្តបាន បានពិពណ៌នារួចហើយ[44] ជំនាញអាជីពរបស់ Lemkin នៅក្នុងការសម្ភាសន៍សាក្សី អាចចាត់ទុកបានថាប្រសើរជាងជំនាញរបស់ Ponchuad ហើយអាចប្រសើរជាងជំនាញរបស់ Heder ផង។ មិនដូច Phillip Short ប្រភពនៃការបកប្រែរបស់ Lemkin- ថេត សម្បត្តិ- ត្រូវបានទទួលស្គាល់ និងអាចទុកចិត្តបាន។ មិនដូចសាក្សីខ្លះដែលបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនេះទេ Lemkin បានថតរូបភាពនៃការសម្ភាសន៍រាល់សាក្សីដែលគាត់ជឿជាក់។ ការសម្ភាសន៍របស់គាត់ធ្វើឡើងក្នុងរង្វង់ពេល១០ឆ្នាំ នៅថ្មីៗជាងការសម្ភាសន៍របស់ Ponchuad, Short ឬ Heder។ ហេតុដូច្នេះវាគ្មានមន្ទិលសង្ស័យទេថា កំណត់ត្រានេះគឺជាស្នាដៃពីការត្រិះរិះរបស់ Lemkin តាមរយៈការពិនិត្យឡើងវិញច្រើនលើកច្រើនសារយ៉ាងហ្មត់ចត់នៃការសម្ភាសន៍ជាច្រើន ដែលគាត់ចាត់ទុកថាជាស្នូលនៃគំរោងស្រាវជ្រាវរយៈពេលមួយទសវត្សរ៍។ សហព្រះរាជអាជ្ញានឹងស្នើសុំឱ្យអង្គជំនុំជម្រះនេះយល់ឃើញថា ឯកសារនេះអាចទុកចិត្តបានតិចជាងកំណត់ត្រារបស់ Stephen Heder ដែលបានកត់ត្រាទុកពេលគាត់ជានិសិត្សដែលទើបបញ្ចប់

---

[44] សូមមើលកថាខណ្ឌ ១១ ដល់ ១២ ខាងលើ។

ថ្នាក់មហាវិទ្យាល័យក្នុងវ័យម្ភៃឆ្នាំកាលពី៣៦ឆ្នាំកន្លងទៅ ស្របពេលគាត់និយាយភាសាដែលមិនជាភាសាកំណើតរបស់គាត់ទៅកាន់មនុស្សចំណែកនៅជំរុំជនភៀសខ្លួននៅព្រំដែនថៃ[45]។

១៩. សហព្រះរាជអាជ្ញាប្ដូរស្នៀតពីភាពមិនសមហេតុសមផល ទៅជាការមិនពិតជាក់ស្ដែងនៅក្នុងការអះអាងថា "Short, Ponchuad និង Heder បានផ្ដល់ដល់អង្គជំនុំជម្រះសាលាដំបូងនូវអត្តសញ្ញាណនៃប្រភពសំខាន់ៗលើបញ្ហានានាដែលពួកគេបានផ្ដល់សក្ខីកម្ម"[46]។ តាមពិតសាក្សីទាំងបីនាក់បានផ្ដល់សក្ខីកម្មដោយផ្អែកលើការសម្ភាសន៍មនុស្សអនាមិក ដែលអង្គជំនុំជម្រះនេះបានពឹងផ្អែកយ៉ាងច្រើន[47]។ Ponchuad ផ្ដល់សក្ខីកម្មនៅសវនាការថា គាត់មិនច្បាស់ពីអត្តសញ្ញាណរបស់ប្រភពភាគច្រើននៅក្នុងការសម្ភាសន៍របស់គាត់នៅក្នុងសំណុំរឿង[48]។ នៅពេលស្នើសុំឲ្យផ្ដល់សេចក្ដីលំអិតបន្ថែមអំពីអត្តសញ្ញាណរបស់អ្នកដែលត្រូវសម្ភាសន៍ម្នាក់ដែលពិពណ៌នានៅក្នុងកំណត់ហេតុរបស់គាត់ថា គ្រាន់តែជា "បុរសម្នាក់មកពីតំបន់១៣" Stephen Heder ថ្លែងថា "ខ្ញុំមានចាំស្រពិចស្រពិលនៃរូបរាងរបស់បុរសម្នាក់នេះ តែខ្ញុំមិនអាចប្រាប់លោកបន្ថែមទេ"[49]។ នៅក្នុងសាលក្រមជារឿយៗអង្គជំនុំជម្រះសាលាដំបូងជឿលើការសម្ភាសន៍មនុស្សអនាមិក[50]។

២០. ប៉ុន្តែវាជាការប្រព្រឹត្តរបស់អង្គជំនុំជម្រះសាលាដំបូងលើព័ស្តុតាងរបស់ Phillip Short ដែលបង្ហាញយ៉ាងច្បាស់នូវភាពមិនខុសគ្នាពីប្រភពនៃភស្តុតាងជាពាក្យចចាមអារាម។ ដូចដែលបណ្ដឹងសាទុក្ខបង្ហាញ អង្គជំនុំជម្រះសាលាដំបូងពឹងផ្អែកលើការសន្ទនារបស់ Short ជាមួយ

---

[45] E3/1714 ERN 00170693 (កត់សំគាល់ឆ្នាំរបស់ឯកសារ ១៩៨០-បានពិពណ៌នា Heder ថាជា "និសិត្សដែលទើបបញ្ចប់សិក្សាថ្នាក់មហាវិទ្យាល័យ" នៅសកលវិទ្យាល័យ Cornell) សូមមើលផងដែរ T-ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៣ (Stephen Heder E1/221.1) pp 26-28 (Heder ជាទូទៅសម្ភាសន៍ជាភាសាខ្មែរ ហើយថតចម្លើយជាភាសាអង់គ្លេស។ Heder មិនទាន់ និយាយស្ទាត់ភាសាខ្មែរនៅឡើយទេ នៅពេលគាត់ចាប់ផ្ដើមសម្ភាសន៍នៅព្រំដែនថៃនៅឆ្នាំ១៩៧៨។)

[46] ចម្លើយតបនៅកថាខណ្ឌ១១។

[47] ជាទូទៅសូមមើលបណ្ដឹងសារទុក្ខ នៅកថាខណ្ឌ១៦៤ និង ជើងទំព័រលេខ៤២៣។

[48] T-ថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៣ ( Francois Ponchaud, E1/179.1), p 96; E3/4590, "រឿងរ៉ាវរបស់ជនភៀសខ្លួន" (ការសម្ភាសន៍ជនភៀសខ្លួនដោយ Ponchaud), ERN 0082319-2.

[49] T-ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៣ (Stephen Heder E1/221.1) pp 107

[50] សូមមើលជាទូទៅនៅក្នុងបណ្ដឹងសារទុក្ខ កថាខណ្ឌ១៦៤, ១៧០។

"អ្នកស្រុក" មិនបង្ហាញឈ្មោះ ជាព័ស្តុតាងតែមួយគត់ដែលថា ទាហានសាធារណរដ្ឋខ្មែរត្រូវបានសម្លាប់នៅឧដុង្គក្នុងឆ្នាំ១៩៧៤។ តែ Short មិនត្រឹមតែមិនអាច "ពិពណ៌នា កំណត់អត្តសញ្ញាណ ឬ សូម្បីតែចាំការសន្ទនានេះ លើកលែងតែសម្រង់តាមរយៈការយោងទៅលើ end note នៅក្នុងសៀវភៅរបស់គាត់" សក្ខីកម្មពិតប្រាកដរបស់គាត់អំពីអ្វីដែល"អ្នកស្រុក"ទាំងនេះបានប្រាប់គាត់ គឺ "នៅត្រង់នេះ លោកដឹង ១២ឆ្នាំក្រោយ ខ្ញុំភ័យខ្លាច ខ្ញុំមិនអាចជួយបានទេ"[51]។ វាមិនអាចទៅរួចទេថា អង្គជំនុំជម្រះសាលាដំបូងស្វែងរកការវាយតម្លៃភាពអាចទុកចិត្តបាននៃការសន្ទនានេះ ដែលអ្នកស្រុកអាថ៌កំបាំងទាំងនេះអាចប្រាប់ Short អំពីការសម្លាប់ទាហានសាធារណរដ្ឋខ្មែរ ពិព្រោះ Short មិនដែលផ្តល់សក្ខីកម្មថាមានការសន្ទនាបែបនេះ។ ការពិតដែលថាអង្គជំនុំជម្រះសាលាដំបូង បានទទួលស្គាល់នៅក្នុងកថាខណ្ឌ ៣២នៃសាលក្រមករបស់ខ្លួនដែលមានម្រាស់ជិត៧00ទំព័រ ថាបទដ្ឋានអន្តរជាតិតម្រូវថាការវាយតម្លៃព័ស្តុតាងត្រូវធ្វើដោយប្រុងប្រយ័ត្នជាអប្បបរមា ។

២១. សហព្រះរាជអាជ្ញាបន្តលំនាំនៃការបំភាន់នេះ ជាមួយនឹងការអះអាងមិនមានមូលដ្ឋានរបស់ពួកគេថា Lemkin និងចេត "ជាបឋមបានបង្ហាញ...អ្នកត្រូវសម្ភាសន៍(interviewee) [redacted]។ ពុំមានចំណុចណាមួយនៅក្នុងកំណត់ត្រាលើកឡើងថា Lemkin បង្ហាញអ្នកត្រូវគេសម្ភាសន៍នូវ [redacted] នៅមុនការសម្ភាសន៍ឡើយ។ នេះគឺជាការអនុវត្តបម្រុងទុកសម្រាប់សហចៅក្រមស៊ើបអង្កេត ដែលជម្រុញឲ្យសាក្សី មាស រឿន ឆ្លើយតាមរយៈសំណួរនាំមុខ ដោយផ្អែកលើព័ត៌មានពីចម្លើយសារភាពរបស់ Chou Chet នៅក្នុងការប៉ុនប៉ងមួយដើម្បីទាញយកការបញ្ជាក់របស់គាត់ថា នួន ជា មានវត្តមាននៅកិច្ចប្រជុំមួយរបស់ភូមិភាគបស្ចិមក្នុងឆ្នាំ១៩៧៧[53]។ ផ្ទុយមកវិញវាសមហេតុសមផលទាំងស្រុងសម្រាប់ Lemkin និង ចេត ដើម្បីបង្ហាញអ្នកត្រូវសម្ភាសន៍នូវ [redacted]។ នៅក្នុងករណីណាក៏ដោយវាចម្លែកក្នុងការសន្និដ្ឋានថា សាក្សីទាំង

---

[51] បណ្តឹងសារទុក្ខបៅកថាខណ្ឌ១៧0, ៥៣២។

[52] ចម្លើយតប កថាខណ្ឌ១៧។

[53] E3/80, ERN 004991657

នេះបានប្រឌិតរឿងរ៉ាវលំអិតនៃព្រឹត្តិការណ៍ជាក់លាក់ដែលពួកគេឃើញនឹងភ្នែក បន្ទាប់ពីបានឃើញ [redacted] ដោយសារព្រឹត្តិការណ៍ទាំងនេះស្របជាមួយការថ្លែងជាក់លាក់នៅក្នុង [redacted]។ វាក៏ចម្លែកផងដែរក្នុងការនិយាយថា សហព្រះរាជអាជ្ញាបញ្ជាក់នៅក្នុងចម្លើយតបរបស់ខ្លួនថា "កត្តាជំរុញរបស់សាក្សីក្នុងការនិយាយជាមួយផលិតករគឺមិនត្រូវបានដឹង" ដែលជាការបារម្ភមួយដែលសហព្រះរាជអាជ្ញាមិនទាំងដែលបានគិតទាល់តែសោះទៅលើសាក្សីរាប់ពាន់នាក់ដែលភស្តុតាងរបស់គាត់ត្រូវបានទទួលយកក្នុងសំណុំរឿងនេះ។

**ឃ. កំណត់ត្រានេះ អាចជាកត្តាសម្រេចនៅការជំនុំជម្រះ**

២២. ដូចដែលសំណើបង្ហាញលំអិតកំណត់ត្រារបស់ Lemkin ផ្តល់នូវរឿងរ៉ាវច្រើននៃអង្គហេតុសំខាន់ពីសាក្សីដែលស្ថិតក្នុងស្ថានភាពល្អ ដែលអាចនិយាយផ្ទុយពីការរកឃើញសំខាន់ៗភាគច្រើនរបស់អង្គជំនុំជម្រះសាលាដំបូង ទាក់ទងនឹងរចនាសម្ព័ន្ធរបស់ ប.ក.ក។ [redacted] នៅក្នុងសាលក្រម អង្គហេតុទាំងនេះបង្កើតបានជាការងាកចេញភ្លាមៗពីបក្សដែលត្រូវបានរៀបចំឡើងយ៉ាងប៉ិនប្រសប់ ជាអង្គភាពដែលមានរចនាសម្ព័ន្ធ "ឋានានុក្រម"តឹងរ៉ឹង និង"មានទម្រង់ជាពីរ៉ាមីត" ដែលកម្មាភិបាលនៅទូទាំងប្រទេស និងក្នុងអំឡុងពេលនៃរបប ធ្វើសកម្មភាពយ៉ាងខ្ជាប់ខ្ជួនដែលបង្កើតឡើងដោយ ប៉ុល

---

[54] F2/4/3/3/1 សំណើនៅកថាខណ្ឌ៦។

[55] F2/4/3/3/1 សំណើនៅកថាខណ្ឌ៦។

[56] F2/4/3/3/1 សំណើនៅកថាខណ្ឌ៦។

[57] F2/4/3/3/1 សំណើនៅកថាខណ្ឌ៦។

ពត និង នួន ជា[58]។ ដូចដែលបណ្តឹងសាទុក្ខបង្ហាញ ភស្តុតាងដែលលើកមកសំអាងដោយអង្គជំនុំជម្រះសាលាដំបូងនៅក្នុងការគាំទ្រសេចក្តីសន្និដ្ឋានទូលំទូលាយបែបនេះ គឺស្តួចស្តើងសឹងតែបាត់មួយរំពេច[59]។

២៣. ដូចដែលសំណើ និងបណ្តឹងសាទុក្ខបង្ហាញបន្ថែម កំហុសរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងចំណុចនេះ គឺសំខាន់ដល់ការរកឃើញរបស់ខ្លួនទាក់ទងនឹងការទទួលខុសត្រូវបទល្មើស។ អង្គជំនុំជម្រះពឹងផ្អែកដដែលៗលើចរិតលក្ខណៈតឹងរ៉ឹងតាមការសន្មតនៃការរាយការណ៍នៅក្នុង ប.ក.ក ថាជាផ្នែកសំខាន់-អាចជាអំណាចសម្រេច(determinative)- នៃការទទួលខុសត្រូវរបស់ នួន ជា សម្រាប់រាល់ការផ្តន្ទាទោសដែលបញ្ចូលនៅក្នុងសាលក្រម[60]។ សហព្រះរាអាជ្ញា-ដែលទទូចថា កំហុសនេះមិនអាចប៉ះពាល់ដល់សេចក្តីសម្រេច-ជឿយ៉ាងច្បាស់ថាការយោងដដែលៗរបស់អង្គជំនុំជម្រះសាលាដំបូងចំពោះការវិភាគរបស់ខ្លួនលើរចនាសម្ព័ន្ធរបស់ ប.ក.ក នៅទូទាំងការវាយតម្លៃរបស់ខ្លួនលើការទទួលខុសត្រូវបទល្មើសជាបុគ្គលរបស់ នួន ជា មិនបំរើបំណងវិភាគជាក់លាក់ទេ។

២ . សហព្រះរាជអាជ្ញានិយាយតិចតួចអំពីសារធាតុនៃភស្តុតាងដោះបន្ទុកដ៏សំខាន់នេះ។ អំណះអំណាងបឋមរបស់ពួកគេ គឺថាសេចក្តីសម្រេចមួយដើម្បីផ្តួលរំលំ ប៉ុល ពត ដែលសម្រេចដោយកម្មាភិបាលជាន់ខ្ពស់របស់ភូមិភាគពាយព្យ និងភូមិភាគបូព៌ា និងដឹកនាំដោយ [redacted] គឺ "មិនពាក់ព័ន្ធ"ទេ ពិព្រោះវាកើតឡើងនៅខែឧសភា ឆ្នាំ១៩៧៥ ជាជាងខែមេសា ឆ្នាំ១៩៧៥[61]។ តែយុត្តាធិការពេលវេលារបស់សំណុំរឿង០០២/០១ ពង្រីករហូតដល់ឆ្នាំ១៩៧៧ ហើយ នួន ជា ត្រូវបានគេដាក់ឲ្យទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ថា បានប្រព្រឹត្តក្នុងអំឡុងពេលនៃការបំលាស់ទីប្រជាជនដំណាក់កាលទីII ដោយកងទ័ពនៅក្នុងភូមិភាគពីរនេះ។ ម្យ៉ាងទៀតអង្គជំនុំជម្រះសាលាដំបូងបានសម្រេចយ៉ាងទូលំទូលាយ

---

[58] សូមមើលឯកសារ E313 "សាលក្រមនៅក្នុងសំណុំរឿង០០២/០១" ថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ("សាលក្រម") នៅកថាខណ្ឌ២២៣, ៨៥៩-៨៦០។ សូមមើលផងដែរបណ្តឹងសារទុក្ខ នៅកថាខណ្ឌ២២៥-២៤៩។

[59] បណ្តឹងសារទុក្ខនៅកថាខណ្ឌ២២៥-២៤៩ ។

[60] បណ្តឹងសារទុក្ខនៅកថាខណ្ឌ២២៦។

[61] ចម្លើយតបនៅកថាខណ្ឌ២៧-២៨។

ទាក់ទងនឹងគោលនយោបាយរបស់ ប.ក.ក ក្នុងការកំណត់គោលដៅវាយប្រហារលើទាហាន និងមន្ត្រីរបស់សាធារណរដ្ឋខ្មែរ "នៅទូទាំងសម័យកម្ពុជាប្រជាធិបតេយ្យ"[62]។ ផ្នែកច្រើនបំផុតនៃភស្តុតាងតាមការសន្នត់ពីការណែនាំរបស់មជ្ឈឹមបក្សក្នុងចំណុចនេះ គឺមានកាលបរិច្ឆេទតាំងពីខែមិថុនា ឆ្នាំ១៩៧៥ ឬក្រោយមកទៀត[63] តែអង្គជំនុំជម្រះសាលាដំបូងពឹងផ្អែកលើភស្តុតាងតាមការសន្នត់នៃការកំណត់គោលដៅវាយប្រហារនៅចុងឆ្នាំ ១៩៧៥, ១៩៧៦ និងក្រោយមកទៀត[64] និងពឹងផ្អែកផងដែរទៅលើភស្តុតាងនៅក្រោយមកទៀតរាប់ទាំងភស្តុតាងពីឆ្នាំ១៩៧៨[65] និងរហូតដល់ចុងឆ្នាំ ១៩៧៩[66]។ សហព្រះរាជអាជ្ញាលើកអំណះអំណាងនៅក្នុងចម្លើយតបរបស់ពួកគេទៅនឹងបណ្តឹងសាទុក្ខថា សារណាលំអិតរបស់យើងខ្ញុំទាក់ទងនឹងភស្តុតាងពីការណែនាំរបស់បក្សនៅទូទាំងឆ្នាំ១៩៧៥ ត្រូវបានណែនាំខុស ពិព្រោះ "ការរកឃើញពិតរបស់អង្គជំនុំជម្រះ គឺផ្អែកលើការពិនិត្យឡើងវិញនៃភស្តុតាងទាំងមូល"[67]។ សញ្ញាណដែលថា ភស្តុតាងផ្ទាល់របស់ Lemkin ដែលថា [redacted] មិនអាចមានអនុភាពលើសាលក្រមទេ ពិព្រោះវាបានកើតឡើងនៅខែឧសភា ជាជាងខែមេសា។

២៥. ជំនួសការលើកឡើងពីសារធាតុរបស់ភស្តុតាង សហព្រះរាជអាជ្ញាប្រើចម្លើយតបភាគច្រើនរបស់ពួកគេដល់កិច្ចប្រឹងប្រែងដើម្បីធ្វើឲ្យអប្បយសកំណត់ត្រារបស់ Lemkin ដោយការធ្វើសន្និដ្ឋាននូវអត្ថិភាពនៃកំហុសតាមការសន្នត់ ដែលមិនមានផង។ ជាដំបូងសហព្រះរាជអាជ្ញាអះអាងថា នៅពេលដែល Lemkin អះអាងថាគណៈអចិន្ត្រៃយ៍ [redacted]។ វាច្បាស់ណាស់ថាភាពមិន

---

[62] សាលក្រម នៅកថាខណ្ឌ៨១៥។

[63] **E313** សាលក្រម នៅកថាខណ្ឌ៨១៧។

[64] **E313** សាលក្រម នៅកថាខណ្ឌ៨៣៣។

[65] សូមមើល ឧទាហរណ៍ដូចជា **E313** សាលក្រម ជើងទំព័រ ១០៣៨។

[66] សូមមើល ឧទាហរណ៍ដូចជា **E313** សាលក្រម ជើងទំព័រ ៩១០។

[67] **F17/1** នៅកថាខណ្ឌ៣៦៦។

[68] ចម្លើយតបនៅកថាខណ្ឌនៅកថាខណ្ឌ២៤។

ត្រឹមត្រូវតាមការសន្មត់ទាក់ទងនឹង [redacted]។ សហព្រះរាជអាជ្ញាត្រូវតែមិនជូនដំណឹងដូចគ្នានៅឡើយ ពិព្រោះពួកគេក៏អះអាងថា [redacted]។ ការខកខានរបស់ពួកគេក្នុងការជូនដំណឹងអង្គជំនុំជម្រះនេះថា ពួកគេខ្លួនឯងជឿថា [redacted] ហើយស្របពេលជាមួយគ្នាថ្កោលទោស Lemkin ទៅវិញចំពោះការសន្និដ្ឋានដូចគ្នាកំពុងបង្កើតជាក្តីកង្វល់។ ការអានរបស់ពួកគេនៃកំណត់ត្រាធ្វើឱ្យបាត់បន្ថែមទៀតនូវអត្ថន័យជាក់ស្តែងរបស់ Lemkin [redacted]

២៦. ស្រដៀងគ្នានេះដែរសហព្រះរាជអាជ្ញា ត្អូញត្អែរថា កំណត់ត្រាមិនអាចទុកចិត្តបានពិព្រោះ Lemkin ថ្លែងថាគណៈមជ្ឈឹម [redacted] ខណៈដែលអង្គជំនុំជម្រះសាលាដំបូងរកឃើញថា គណៈកម្មាធិការនេះមានសមាជិកមិនលើសពី៣០នាក់ទេ[71]។ មានតែសាក្សីមួយនាក់គត់ដែលអាចជឿទុកចិត្តបាន ដែលត្រូវបានលើកមកសំអាងដោយអង្គជំនុំជម្រះសាលាដំបូង-ខៀវ សំផន- បានផ្តល់សក្ខីកម្មថា "គណៈមជ្ឈឹមមានសមាជិកច្រើនជាង៣០នាក់"[72]។ ហេតុនេះវាមិនមែន Rob Lemkin ទទួលបានព័ត៌មានខុសទេ តែចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងទៅវិញទេ ដែលទទួលបានព័ត៌មានខុស។ ម្យ៉ាងទៀតដូចដែលការពិភាក្សារបស់ Lemkin [redacted] រូបនៃគណៈអចិន្ត្រៃយ៍ បង្ហាញ [redacted]

---

[69] ចម្លើយតបនៅកថាខណ្ឌនៅកថាខណ្ឌ២៤ ជើងទំព័រលេខ៦៣។

[70] T30 តុលា ២០១៣ (ចម្លើយតបរបស់សហព្រះរាជអាជ្ញា E1/236.1), p 118.

[71] **F2/4/3/3/3**, ចម្លើយតបនៅកថាខណ្ឌ២៥។ E313, សាលក្រមនៅកថាខណ្ឌ២០២។

[72] **E3/27** "កំណត់ហេតុលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយជនត្រូវចោទ-ខៀវ សំផន ហៅ ហែម" ចុះថ្ងៃទី១៣ ខែធ្នូ ២០០៧, ERN (En) 00156751។ ព័ស្តុតាងមួយទៀតដែលលើកមកសំអាងដោយអង្គជំនុំជម្រះសាលាដំបូង ផ្តល់ដោយមនុស្សម្នាក់ដែលត្រូវបានសម្ភាសន៍ដោយ Heder នៅព្រំដែនថៃ លើកឡើងថា មានសមាជិក "ប្រហែល" ៣០នាក់ ហើយមានមនុស្ស៦០នាក់ចូលរួមកិច្ចប្រជុំមួយ ដែលនេះបង្ហាញពីភាពប្រែប្រួលនៃសមាជិកភាពរបស់គណៈកម្មាធិការនេះ។ សូមមើលឯកសារ E3/1714, ERN 00170750

[redacted] ដែលជាការអះអាងត្រឹមត្រូវបំផុតសមស្របតាមការរកឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា "អត្តសញ្ញាណ និងចំនួនសមាជិក បានប្រែប្រួលច្រើនលើកច្រើនសារវាងឆ្នាំ១៩៦០ និងឆ្នាំ១៩៧៩"[73]។

២៧. សហព្រះរាជអាជ្ញាអះអាងបន្ថែមទៀតថា ការវិភាគរបស់ Lemkin គឺមិនអាចទុកចិត្តបាន ពិព្រោះគាត់ហាក់ដូចជាដាក់ "ការជឿដ៏ធំ" នៅក្នុងការអះអាងដែលថា [redacted]។ សហព្រះរាជអាជ្ញាឲ្យគេយល់ថា ទស្សនរបស់ Lemkin នៅក្នុងចំណុចនេះប្រហែលជាចេញពី នួន ជា ដែលពួកគេថ្លែងបញ្ជិតថា Lemkin គឺគ្រាន់តែថាតាមដូចសត្វសេក[75]។ ផ្ទុយពីការអះអាងរបស់សហព្រះរាជអាជ្ញា ការវិភាគរបស់ Lemkin គឺមានហេតុផល មានតុល្យការ ហើយមិនបានបង្ហាញ "ការជឿ" របស់គាត់នៅក្នុងអ្វីទាំងអស់។ Lemkin គ្រាន់តែរ៉ាយរាប់រឿងរ៉ាវផ្ទាល់របស់សាក្សី [redacted] Lemkin ពិពណ៌នាដោយត្រង់ៗពីយោបល់របស់ នួន ជា នៅក្នុងចំណុចនេះ ដោយបានបិទបាំងការលើកឡើងស្ដែងៗរបស់សហព្រះរាជអាជ្ញាថា គាត់គ្មានបានធ្វើអ្វី ក្រៅពីថាឡើងវិញនូវអ្វីដែល នួន ជា បានប្រាប់គាត់។ Lemkin អះអាងបន្ថែមនៅក្នុងលំដាប់លំដោយ ដូចគ្នាថា [redacted]។ Lemkin សន្និដ្ឋានដូចខាងក្រោម: [redacted]

---

[73] E313, សាលក្រមនៅកថាខណ្ឌ២០២។

[74] F2/4/3/3/3, ចម្លើយតបនៅកថាខណ្ឌ២៣។

[75] F2/4/3/3/3, ចម្លើយតបនៅកថាខណ្ឌ២៣។

[76] F2/4/3/3/1, សេចក្ដីពន្យល់ ERN 01106930

[redacted]។ ការលាបពណ៌របស់សហព្រះរាជអាជ្ញាមកលើ Lemkin ថាជាអ្នកសម្តែងមតិឲ្យអ្នកដ៏ទៃដែលងាយឲ្យគេបោកប្រាស់សម្រាប់ការតវ៉ារបស់ នួន ជា ពីភាពគ្មានទោសរបស់គាត់ គឺជារឿងមិនទំនងសោះ។

២៨. អំណះអំណាងរបស់សហព្រះរាជអាជ្ញាហាក់ដូចជាថា ការសម្ភាសន៍ត្រូវតែខុស ពិព្រោះការសម្ភាសន៍ទាំងនេះផ្ទុយពីទម្រង់នៃព្រឹត្តិការណ៍របស់សហព្រះរាជអាជ្ញា-ទម្រង់ព្រឹត្តិការណ៍ដែលពួកគេសារភាព នៅពេលនេះគឺមានវិវាទនៅឡើយនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង០០២/០២។ ពួកគេអះអាងថា ដោយសារសាក្សីមួយចំនួនបានពិពណ៌នាថា [redacted]។ សហព្រះរាជអាជ្ញាប្រាកដណាស់ថា តក្កសាស្ត្រនេះ មិនអាចបដិសេធបានដោយសាររឿងរ៉ាវផ្ទាល់របស់សាក្សីម្នាក់ ដែលត្រូវបាន [redacted] មិនមានសិទ្ធិស្នូម្បីទទួលបានការប្រព្រឹត្តដោយប្រយ័ត្នប្រយែងដូចនៅក្នុងសេចក្តីពន្យល់របស់ Lemkin។ ហេតុផលរបស់សហព្រះរាជអាជ្ញាផ្ទុះបញ្ចាំងពីលក្ខណៈសំដីទូទៅនៃកិច្ចដំណើរការនីតិវិធីនៅក្នុងសំណុំរឿង០០២/០១ និងការរកឃើញភាគច្រើននៅក្នុងសាលក្រម អនុលោមតាមភស្តុតាងដែលចាត់ទុកថាមិនអាចទុកចិត្តបាន ពិព្រោះវាជាភស្តុតាងដោះបន្ទុក[78]។ វាអាចជាផ្លូវមានប្រសិទ្ធិមួយដើម្បីទទួលបានការផ្តន្ទាទោស តែវាពិបាកបង្កើតបានមូលហេតុផ្នែកច្បាប់។

២៩. ជាចុងក្រោយអំណះអំណាងរបស់សហព្រះរាជអាជ្ញាថា ភស្តុតាងនៃការសម្ភាសន៍របស់ Lemkin គឺមិនអាចទុកចិត្តបាន ពិព្រោះការអះអាងដែលថា [redacted] គឺមិនស៊ីសង្វាក់ជាមួយភស្តុតាងដែលបង្ហាញថា [redacted] ការលើកឡើងបែបនេះគួរឲ្យសង្ស័យ។ មិនមានអ្វីដែលមិនស្របរវាងអង្គហេតុដែលថា [redacted]

---

[77] F2/4/3/3/1, សេចក្តីពន្យល់ ERN 01106931

[78] សូមមើល ឧទាហរណ៍ F16 បណ្តឹងសារទុក្ខនៅកថាខណ្ឌ២២១, ៥៤៦។

[79] F2/4/3/3/3, ចម្លើយតបនៅកថាខណ្ឌ៣១-៣៣។

[redacted] តាតពិតអង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ថា កំលាំងទ័ពដែលទុកឲ្យក្រោមការគ្រប់គ្រងរបស់ភូមិភាគ សម្រាប់តែគោលបំណងការពារទឹកដីប៉ុណ្ណោះ[80]។ [redacted] -ដូចដែលបញ្ជាក់នៅក្នុងកិច្ចសម្ភាសន៍របស់ Lemkin និង ថេត សម្បត្តិ ។

## ង. សេចក្ដីពន្យល់មិនពឹងផ្អែកចម្លើយសារភាពនៅមន្ទីរ ស២១ ទេ

៣០. សហព្រះរាជអាជ្ញារិះគន់បន្ថែមទៀតលើស្នាដៃរបស់ Lemkin និង ថេត សម្បត្តិ ពីព្រោះសេចក្ដីពន្យល់យោង [redacted]។ សហព្រះរាជអាជ្ញានៅតែសារភាពថា Lemkin ពឹងផ្អែក [redacted] គ្រាន់តែជា "ការបញ្ជាក់" សម្រាប់រឿងរ៉ាវផ្ទាល់ដែលផ្ដល់ដោយអ្នកត្រូវសម្ភាសន៍ម្នាក់របស់គាត់ ហើយតាមពិតការយោងរបស់ Lemkin ចំពោះ [redacted] បន្ទាប់ពីការពិពណ៌នាលើខ្លឹមសារនៃការសម្ភាសន៍នោះ[82]។ នេះគឺជាការប្រើប្រាស់ភស្តុតាងពាក់ព័ន្ធដ៏កម្រិត និងសមហេតុសមផលទាំងស្រុងដោយអ្នកស្រាវជ្រាវ ដែលធ្វើការក្រៅក្របខណ្ឌនៃកិច្ចដំណើរការច្បាប់។

៣១. តាមពិតការប្រើប្រាស់ចម្លើយសារភាពនៅស២១ ដើម្បីធ្វើជាមគ្គុទ្ទេសក៏សម្រាប់ការស្រាវជ្រាវកម្ពុជាប្រជាធិបតេយ្យ ត្រូវបានអនុវត្តជាទូទៅដោយ academics និងអ្នកស៊ើបអង្កេតនៅសាលាក្ដីនេះ ។ ដូចបានកត់សម្គាល់រួចហើយ ក្នុងអំឡុងពេលការស្ដាប់ចម្លើយដែលជាផ្នែកនៃកិច្ចស៊ើបសួរក្នុងសំណុំរឿង សហចៅក្រមស៊ើបអង្កេតខ្លួនឯងបានប្រើចម្លើយសារភាពនៅក្នុងការប្រឹងប្រែងដើម្បីទាញយកសក្ខីកម្មដាក់បន្ទុក[83]។ អ្នកស្រាវជ្រាវជាច្រើនផ្សេងទៀត

---

[80] E313 សាលក្រមនៅកថាខណ្ឌ២៤៥។

[81] F2/4/3/3/3, ចម្លើយតបនៅកថាខណ្ឌ៣១-៣៣។

[82] F2/4/3/3/1, សេចក្ដីពន្យល់ ERN 01106929

[83] សូមមើលកថាខណ្ឌ២១ ខាងលើ។

បានពឹងផ្អែកយ៉ាងខ្លាំងលើចម្លើយសារភាពនៅស២១ ដើម្បីបង្កើតមតិអំពីកម្ពុជាប្រជាធិបតេយ្យ ជាពិសេស Stephen Heder ចម្លើយសារភាពបង្កើតបានជាមូលដ្ឋានដ៏សំខាន់នៃការយល់ដឹងរបស់គាត់ទាំងស្រុងអំពី ប.ក.ក។ នៅក្នុងសុន្ទរកថាមួយនៅឆ្នាំ២០០១ Heder ពិពណ៌នាការប្រើប្រាស់ចម្លើយសារភាពនៅស២១។ គាត់ពន្យល់:

> តាមរយៈឯកសារមួយពាន់ទំព័រដំបូង វាក្លាយជាការពិតជាក់ស្តែងចំពោះអ្នកអានថា វាគ្មានមន្ទិលសង្ស័យទេថា វាជារឿងពិត។ ការវាយតម្លៃនេះ គឺផ្អែកលើការយល់ដឹងជារួម។ អ្វីដែលនិយាយលើសារព័ត៌មានហាក់ដូចជារឿងសាមញ្ញ និងការជាថ្លែងចំៗ ។ នៅចុងបញ្ចប់នៃវិសាលគម គឺចម្លើយជាច្រើនអាចត្រូវបានវិនិច្ឆ័យថា មានភាពជឿជាក់ច្រើនបំផុតបាន[84]។

សហព្រះរាជអាជ្ញាហាក់ដូចជាជឿថា "ការជឿជាក់លើភាពអាចទុកចិត្តបាន និងតម្លៃភវនីយភាពរបស់ស្នាដៃទាំងស្រុងរបស់ Heder"[85]-យ៉ាងហោចណាស់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបអង្កេត និង ដីកាដំណោះស្រាយ។

## III. សេចក្តីសន្និដ្ឋាន និង សំណើសុំដំណោះស្រាយ

៣២. ការខុសពីភាពដើម ការផ្លាស់ប្តូរ និង ការបំភាន់ ដែលត្រូវបានកំណត់ស្ទើរតែគ្រប់កថាខណ្ឌនៃចម្លើយតបនេះ គាំទ្រតិចបំផុតដល់អំណះអំណាងរបស់សហព្រះរាជអាជ្ញា។ ប៉ុន្តែវានិយាយច្រើនអំពីសារសំខាន់របស់ភស្តុតាងរបស់ Lemkin ។ សហព្រះរាជអាជ្ញាត្រូវការដកកំណត់ត្រានេះចេញពីភស្តុតាង ដោយសារពួកគេយល់យ៉ាងច្បាស់ពីការជំពាក់ជំពិនរបស់សម្រាប់ការសម្រេចនៅក្នុងសាលក្រម។ ជាអភ័ព្វសហព្រះរាជអាជ្ញាហាក់ដូចជាស្ទាក់ស្ទើរក្នុងការអនុវត្តតួនាទីរបស់ពួកគេដើម្បីបញ្ជាក់ការពិត ដូច្នេះវាចាំបាច់សម្រាប់អង្គជំនុំជម្រះនេះដើម្បីធានាថាកំណត់ហេតុនេះ ត្រូវបានទទួលយកជាភស្តុតាង ហើយផ្តល់ការពិចារណាឲ្យបានសមរម្យ និងយកចិត្តទុកដាក់ឲ្យបានគ្រប់គ្រាន់ដល់កំណត់ហេតុនេះ នៅកិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខ។

៣៣. ក្រុមមេធាវីការពារក្តីស្នើសុំអង្គជំនុំជម្រះតុលាការកំពូល:

---

[84] Stephen Heder *ខ្មែរក្រហមប្រឆាំង ប៉ុល ពត: គាំទ្រវៀតណាម ឬ គាំទ្រចិន (២០០១)។*

[85] F2/4/3/3/3, ចម្លើយតបនៅកថាខណ្ឌ៣០។

(ក) បដិសេធចោលអំណះអំណាងនៅក្នុងចម្លើយតប និង

(ខ) អនុញ្ញាតដំណោះស្រាយដែលបានស្នើសុំនៅក្នុងសំណើ។

**សហមេធាវីការពារក្តីលោក នួន ជា**

**សុន អរុណ** Victor KOPPE